ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ:..៥៧០...សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១០

# ប្រកាស
# ស្តីពី
# នីតិវិធីតវ៉ាប្រឆាំងកំណត់ហេតុគយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ .-**

បុគ្គលដែលត្រូវរងនូវទោសទណ្ឌ ឬការឃាត់ទុកនូវទំនិញ មធ្យោបាយដឹកជញ្ជូន ឬវត្ថុផ្សេងទៀត អាចតវ៉ាជាលាយលក្ខណ៍អក្សរទៅ អគ្គនាយកគយ និងរដ្ឋាករកម្ពុជា ក្នុងអំឡុងពេលសាមសិប ( ៣០ ) ថ្ងៃ ក្រោយពីបានទទួលសេចក្តីជូនដំណឹងពីទោសទណ្ឌ ឬ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92. Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

ការឃាត់ទុក ដោយបញ្ជាក់ ពីមូលហេតុនៃការតវ៉ា និងតម្កល់និមុត្តិជានាស្របតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ស្តីពីគយ ។

**ប្រការ ២.-**

អគ្គនាយកគយ និងរដ្ឋាករកម្ពុជា ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើការតវ៉ាក្នុងអំឡុងពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលពាក្យតវ៉ា បើមិនដូច្នោះទេ ការតវ៉ានោះត្រូវបានចាត់ទុកថា បានទទួលការយល់ព្រម ។

**ប្រការ ៣ .-**

ការតវ៉ាអាចត្រូវបានតម្កល់នៅតាមអង្គភាពគយ ដូចខាងក្រោម ៖

- ការិយាល័យគយដែលតាក់តែងកំណត់ហេតុ ឬកំណត់ការពិន័យ
- សាខាគយ និងរដ្ឋាករពាក់ព័ន្ធ
- ការិយាល័យកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- លេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។

បន្ទាប់ពីបានទទួលការតវ៉ា អង្គភាពគយពាក់ព័ន្ធត្រូវបញ្ជូនលិខិតសុំតវ៉ានោះដោយមិនបង្អែបង្អង់ជូនអគ្គនាយកគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៤ .-**

លិខិតសុំតវ៉ាត្រូវមានទូវព័ត៌មានដូចតទៅ ៖

- នាម អាសយដ្ឋាន និងហត្ថលេខា របស់បុគ្គលដែលតម្កល់ការតវ៉ា
- សេចក្តីលម្អិតនៃកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុឃាត់ទុកបណ្តោះអាសន្ន រាប់បញ្ចូលទាំងសេចក្តីថតចម្លងកំណត់ហេតុទាំងនេះ
- សេចក្តីពន្យល់អំពីមូលហេតុនៃការតវ៉ា ។

**ប្រការ ៥ .-**

ប្រសិនបើទំនិញឃាត់ទុកបណ្តោះអាសន្នមិនជាប់អាយ័ត ទំនិញ មធ្យោបាយដឹកជញ្ជូន ឯកសារ និងវត្ថុចាប់ឃាត់ផ្សេងទៀតមិនតម្រូវសម្រាប់ជាភស្តុតាង វត្ថុឃាត់ទុកទាំងនេះអាចត្រូវបានប្រគល់ទៅម្ចាស់ ក្រោយពេលបានតម្កល់នូវនិមុត្តិជានាដូចមានចែងក្នុងបញ្ញត្តិនៃប្រកាសស្តីពីនិមុត្តិជានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបញ្ញត្តិមាត្រា ៤១ នៃច្បាប់ស្តីពីគយ។

ប្រសិនបើអគ្គនាយកគយ និងរដ្ឋាករកម្ពុជា មិនយល់ព្រមតាមការតវ៉ាទេ បុគ្គលដែលបានដាក់ពាក្យតវ៉ា មានសិទ្ធិតវ៉ាទៅស្ថាប័នមានសមត្ថកិច្ច រាប់បញ្ចូលទាំងតុលាការមានសមត្ថកិច្ច ចំពោះការសម្រេចរបស់អគ្គនាយកគយ និងរដ្ឋាករកម្ពុជា ។ ការតវ៉ានេះត្រូវធ្វើក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីសម្រេចរបស់អគ្គនាយកគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៦.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧.-**

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី

 "ដើម្បីជូនជ្រាប"

- ដូចប្រការ ៧
- សភាពាណិជ្ជកម្មកម្ពុជា

 "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ